00170459

E11/40

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | | |
|---|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ | : | ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០១) |
| កាលបរិច្ឆេទដាក់សារណា | : | ២២/០២/២០០៨ |
| ចំនួនទំព័រ | : | ៧ |
| ភាសា | : | អង់គ្លេស |
| ដាក់ជូនទៅ | : | អង្គបុរេជំនុំជម្រះ |
| សារណាដាក់ជូនដោយ | : | វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ "KID" |

ចំណងជើងសារណា:

***សារណាសាធារណៈ៖ ជននាក់ទងនឹងការចូលរួមពីភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត***

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 03 / 2008
ម៉ោង (Time/Heure): 9:24 AM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

ដាក់ជូនដោយក្តីគោរពពី:
វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ "KID"

ភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨

សំរាប់ព័ត៌មានបន្ថែម សូមអញ្ជើញទំនាក់ទំនង:
លោក ហង្ស ឆាយ យ៉ា នាយកប្រតិបត្តិKID
ប្រអប់សំបុត្រលេខ:១១៧
ផ្ទះលេខ៥ ផ្លូវលេខ៥៧ សង្កាត់បឹងកេងកងI ភ្នំពេញ
ទូរស័ព្ទលេខ: 023 214 928
ទូរសា: 023 216 206
director.kid@online.com.kh

Original EN: 00164676-00164682

***ផលប្រយោជន៍នៃសារណាសាធារណៈ***

១. វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យគឺជាអង្គការមិនគិតប្រាក់កម្រៃ មិនប្រកាន់បក្សពួកនិយម ធ្វើប្រតិបត្តិការលើសកម្មភាពមួយចំនួនដើម្បីផ្សព្វផ្សាយអំពីការគោរពសិទ្ធិមនុស្ស និងជំរុញលើកទឹកចិត្តឱ្យមានការចូលរួមប្រជាធិបតេយ្យក្នុងសង្គមប្រជាធិបតេយ្យ។

២. គោលដៅជាមូលដ្ឋានមួយ ក្នុងចំណោមគោលដៅជាច្រើនរបស់វិទ្យាស្ថានខ្មែរ ដើម្បីលទ្ធិប្រជាធិបតេយ្យគឺ ត្រូវរាយការណ៍ និងភ្ជាប់ទំនាក់ទំនងពលរដ្ឋកម្ពុជា ទៅក្នុងសកម្មភាពនានានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមរយៈការផ្សព្វផ្សាយការពិភាក្សាអំពីគោលការណ៍ជំនុំជម្រះប្រកបដោយយុត្តិធម៌ ការចូលរួមរបស់ជនរងគ្រោះ ការការពារសាក្សីនិងជនរងគ្រោះ។ ទាក់ទងផ្ទាល់ជាមួយនឹងពលរដ្ឋកម្ពុជាអំពីដំណើរការនៃ អ.វ.ត.ក វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យស្ថិតក្នុងស្ថានភាពពិសេសមួយជាម្ចាស់សារណាសាធារណៈផ្សេងៗទៀតក្នុងការផ្តល់ទស្សនៈ អំពីទំហំនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលជំនុំជម្រះក្តី។

***សេចក្តីថ្លែងអំពីអង្គហេតុ***

៣. នួន ជាបានប្តឹងឧទ្ធរណ៍នឹងដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក សម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ ត្រូវបានគេជូនដំណឹងអំពីភាគីរដ្ឋប្បវេណីចំនួនបួនក្នុងសំណុំរឿងរបស់ នួន ជា ដែលទទួលបានការឯកភាពពីសហចៅក្រមស៊ើបអង្កេត។

៤. អង្គបុរេជំនុំជម្រះត្រូវបានគេជូនដំណឹងអំពីការណាត់ជួបរបស់មេធាវីភាគីរដ្ឋប្បវេណី និងគោលបំណងរបស់ពួកគេក្នុងការបង្ហាញខ្លួននៅឯសវនាការលើបណ្តឹងឧទ្ធរណ៍។ សេចក្តីសម្រេចពីការកំណត់ថ្ងៃបើកសវនាការត្រូវបានកែប្រែដោយអង្គបុរេជំនុំជម្រះ ហើយពេលវេលាត្រូវបែងចែកសំរាប់ការដាក់សារណារបស់ភាគីរដ្ឋប្បវេណី។ អង្គបុរេជំនុំជម្រះ បានបើកសវនាការលើបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយសហមេធាវី នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន នៅថ្ងៃទី ៧-៨ ខែកុម្ភៈ ឆ្នាំ ២០០៨។

*ខ្លឹមសារសង្ខេបនៃសេចក្ដីសំរេច*

I. វិធានផ្ទៃក្នុងរបស់អ.វ.ត.ក(វិធានផ្ទៃក្នុងអ.វ.ត.ក)អនុញ្ញាតឱ្យមានការចូលរួមពេញទំហឹងពីភាគីរដ្ឋប្បវេណី។ ការវិភាគតាមន័យត្រង់និងដោយចេតនាអំពីវិធានផ្ទៃក្នុងរបស់អ.វ.ត.ក បង្ហាញថាភាគីរដ្ឋប្បវេណីមានសិទ្ធិពេញលេញក្នុងការចូលរួមគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់។

II. អ.វ.ត.ក ត្រូវតែអនុវត្តតាមច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលផ្ដល់អំណាចឱ្យអ្នកធ្វើសេចក្ដីសម្រេចមុនការជំនុំជម្រះ ដើម្បីចេញដីកាឱ្យមានការចូលរួមពីភាគីរដ្ឋប្បវេណី ក្នុងកិច្ចដំណើរការសវនាការលើបណ្ដឹងឧទ្ធរណ៍អំពីការឃុំខ្លួនមុនការជំនុំជម្រះ។

III. ការចូលរួមពីភាគីរដ្ឋប្បវេណីក្នុងបណ្ដឹងឧទ្ធរណ៍អំពីការឃុំខ្លួនមុនការជំនុំជម្រះ មិនធ្វើឱ្យប៉ះពាល់ដល់ជនជាប់ចោទឡើយ។

*អំណះអំណាង*

I. **វិធានផ្ទៃក្នុងបង្ហាញថា ភាគីរដ្ឋប្បវេណីអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធី រួមទាំងបណ្ដឹងឧទ្ធរណ៍ផងដែរ**

**ក. ការបកស្រាយតាមន័យត្រង់**

៥. វិធាន២៣[១] នៃអ.វ.ត.ក កំណត់អំពីនីតិវិធីសំរាប់បណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលធ្វើឡើងដោយជនរងគ្រោះ។ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យមិនយល់ស្របនឹងការចង្អុលបង្ហាញរបស់ក្រុមមេធាវីរបស់ នួន ជា អំពីចរិកលក្ខណៈវិធាន២៣នៃអ.វ.ត.ក ដោយការដាក់កម្រិតលើការចូលរួមពីភាគីរដ្ឋប្បវេណីដើម្បីជ្រើសរើសកិច្ចដំណើរការនីតិវិធីទេ។ ពាក្យថា កិច្ចដំណើរការនីតិវិធី ត្រូវគេប្រើប្រាស់ចំនួនប្រាំពីរដងក្នុងវិធាន២៣ ដើម្បីពិពណ៌នាអំពីការចូលរួមរបស់ភាគីរដ្ឋប្បវេណី។ ពាក្យថា កិច្ចដំណើរការនីតិវិធី បង្ហាញពីកិច្ចដំណើរការជាក់លាក់តែម្ដងប៉ុណ្ណោះគឺនៅពេលដែលពិពណ៌នានៅវិធាន២៣.៤ថា ជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរហូតដល់ *ការបើកកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ*។

---

[១] *ចូរមើល*អ.វ.ត.ក: វិធានផ្ទៃក្នុង ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ (វិធានអ.វ.ត.ក) វិធាន២៣។

៦. នៅវិធាន២៣.១ វិធានថែងជាធម្មតាថា គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ វិធាន២៣.៦(ក)ក៏ប្រើប្រាស់ពាក្យទូលាយផងដែរ គឺកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅពេលយោងដល់ជនរងគ្រោះក្លាយខ្លួនជាភាគីមួយ ក្នុងកិច្ចដំណើរការនីតិវិធី នៅពេលទទួលបានការស្គាល់ជាភាគីរដ្ឋប្បវេណី។ វិធាន២៣.៧ យោងទៅលើពាក្យ *កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអ.វ.ត.ក* ចំនួនពីរដងនៅពេលពិពណ៌នា អំពីសិទ្ធិភាគីរដ្ឋប្បវេណីទទួលបានមេធាវី ហើយវិធាន២៣.៧(ង)(២) ប្រើប្រាស់ភាសា *នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី* នៅពេលបញ្ជាក់អំពីសិទ្ធិរបស់មេធាវីជាតិនិយាយមុន។

៧. ក្រឡេកទៅមើលការប្រើប្រាស់ពាក្យ "កិច្ចដំណើរការនីតិវិធី" តាមរយៈវិធានអ.វ.ត.កទាំងមូល វាកាន់តែច្បាស់ថា ពាក្យថា "កិច្ចដំណើរការនីតិវិធី" រួមមាន កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ដូចជា ការស៊ើបអង្កេតរបស់តុលាការ កិច្ចដំណើរការនីតិវិធីអង្គបុរេជំនុំជម្រះ កិច្ចដំណើរការនីតិវិធីសាលាដំបូង។ ផ្នែក ឃ នៃវិធានអ.វ.ត.កមានចំណងជើងថា *កិច្ចដំណើរការនីតិវិធីបុរេជំនុំជម្រះ* និងវិធាន៧៤.៥ យោងដល់កិច្ចដំណើរការស៊ើបអង្កេត។

៨. វិធាន២៣ គឺជាវិធានផ្តល់ការអនុញ្ញាត ពិពណ៌នាអំពីសិទ្ធិ និងសេចក្តីរំពឹងទុកចំពោះការចូលរួមពីភាគីរដ្ឋប្បវេណី។ អានទូវវិធាន២៣ ដោយពិចារណាវិធានផ្សេក្នុងអ.វ.ត.កទាំងមូល បង្ហាញថា សិទ្ធិក្នុងចូលរួមរបស់ភាគីរដ្ឋប្បវេណី ត្រូវគេផ្តល់ឱ្យគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី។

**ខ. ការបកស្រាយដោយចេតនា**

៩. ការបញ្ចូលនូវការចូលរួមពីភាគីរដ្ឋប្បវេណីនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីក៏សមស្របនឹងបំណងគិតទុកអំពីការចូលរួមពីភាគីរដ្ឋប្បវេណីនៅអ.វ.ត.កផងដែរ។ មិនដូចសិទ្ធិចូលរួមពីភាគីរដ្ឋប្បវេណី ដែលត្រូវគេកម្រិតបន្ថែមនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិទេ នៅក្នុងវិធានរបស់អ.វ.ត.ក គេពុំអនុវត្ត ឬពុំមាននីតិវិធីជ្រើសរើសសំរាប់ការចូលរួមពីភាគីរដ្ឋប្បវេណីទេ ក្រៅតែពីការអនុវត្ត និងការទទួលស្គាល់ឋានៈនៃភាគីរដ្ឋប្បវេណីនោះ។

១០. នៅពេលទទួលស្គាល់ជាភាគីមួយ ភាគីរដ្ឋប្បវេណីរក្សាបានឋានៈជាភាគីពេញលេញមួយ ហើយមានសិទ្ធិឱ្យគេបញ្ចូលខ្លួនទៅក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់។ ដូច **ឯកឧត្តម សុខ អាន** បានមានប្រសាសន៍ថា "អ.វ.ត.កបង្កើតឡើងក្នុងប្រព័ន្ធដំណើរការច្បាប់ស៊ីវិលមួយ ដោយមានស្ថាប័ន

និងទស្សនៈជាក់លាក់ទាំងឡាយ មិនមែនបង្កើតឡើងក្រោមច្បាប់Commonទេ ដូចជាការផ្តល់ការចូលរួមពេញលេញពីសំណាក់ជនរងគ្រោះ និងភាគីរដ្ឋប្បវេណី ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។"[២]

១១. នៅសម្រេច អំពីភាពសមស្របនៃការចូលរួមពីភាគីរដ្ឋប្បវេណី ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីអ.វ.ត.ក សំខាន់ គឺត្រូវឆ្លុះបញ្ចាំងអំពីលក្ខណៈពិសេសរបស់អ.វ.ត.កជាផ្នែកមួយ នៃតុលាការរបស់កម្ពុជា។ ដូចឯកឧត្តម សុខ អាន បានមានប្រសាសន៍ថា "អ.វ.ត.ក មានលក្ខណៈពិសេសមួយចំនួន ដូចជា ការពាក់ព័ន្ធយ៉ាងជ្រៅពីភាគីជាតិ និងអន្តរជាតិក្នុងគ្រប់ផ្នែកទាំងអស់របស់តុលាការ។ ដូច្នេះ វាជាតុលាការលើកដំបូងដែលត្រូវបង្កើតឡើង ក្នុងប្រព័ន្ធតុលាការជាតិមួយ ដែលមានឧបញ្ញត្តិជាក់លាក់ ដើម្បីអនុវត្តនីតិវិធីដែលអាចអនុវត្តបានរបស់ជាតិ លើកលែងតែស្ថានភាពមួយចំនួនបានកំណត់ដើម្បីធានាបំពេញឱ្យបាននូវបទដ្ឋានយុត្តិធម៌អន្តរជាតិ"[៣]។

១២. ជាក់ស្តែង នីតិវិធីព្រហ្មទណ្ឌកម្ពុជាទៅហួសពីបទដ្ឋានយុត្តិធម៌អន្តរជាតិបច្ចុប្បន្ន ទាក់ទងនឹងការចូលរួមពីភាគីជនរងគ្រោះ[៤] មាត្រា៦ (ខ) នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ

---

[២] ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី "សន្ទរកថាបើក សន្និសិទព្រះរាជអាជ្ញាអន្តរជាតិលើកទីបួន"ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០៧ អ.វ.ត.ក ភ្នំពេញ។

[៣] *Ibid*។

[៤] មាត្រា ៦(ខ) នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ ស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សំរាប់ជនរងគ្រោះពីឧក្រិដ្ឋកម្មនិងការរំលោភអំណាច តម្រូវឱ្យមានការសម្របសម្រួលដល់ កិច្ចដំណើរការរដ្ឋបាលនិងតុលាការអាចឆ្លើយតបបានទៅនឹងតម្រូវការជនរងគ្រោះ ពោលគឺ៖ អនុញ្ញាតឱ្យជនរងគ្រោះបង្ហាញទស្សនៈនិងការព្រួយបារម្ភរបស់ខ្លួន ហើយត្រូវគេលើកយកទៅពិនិត្យពិចារណានៅក្នុងដំណាក់កាលសមស្របទាំងឡាយនៃកិច្ចដំណើរការនីតិវិធី នៅពេលដែលប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់របស់ពួកគេ ដោយមិនធ្វើឱ្យប៉ះពាល់ដល់ជនរងគ្រោះនិងសមស្របតាមប្រព័ន្ធតុលាការព្រហ្មទណ្ឌជាតិពាក់ព័ន្ធ។ *ចូរមើល* សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សំរាប់ជនរងគ្រោះពីឧក្រិដ្ឋកម្មនិងការរំលោភអំណាច G.A. Res 40/34, U.N. GAOR, 40TH Sess., 96th plenary mtg., ឧបសម្ព័ន្ធ U.N. Doc. A/RES/40/34 (1985)។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការឃុំខ្លួនមុនការជំនុំជម្រះ សូម្បីតែមានការអនុវត្តនូវសិទ្ធិចូលរួមជាមូលដ្ឋាននេះក៏ដោយ ក៏វានៅតែប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់ខ្លួននៃភាគីរដ្ឋប្បវេណីដែរ។ សារណាទាំងឡាយទាក់ទងនឹងមូលហេតុផ្សេងៗនៃការឃុំខ្លួន វិធាន៦៣(៣)មានការជាប់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ខ្លួននៃភាគីរដ្ឋប្បវេណី ដោយហេតុថា មូលហេតុនៃការឃុំខ្លួននោះគឺដើម្បីការពារជនត្រូវចោទពីការដាក់សម្ពាធលើសាក្សី ឬ ជនរងគ្រោះណាម្នាក់។ តាមពិត ភាគីរដ្ឋប្បវេណីមានផលប្រយោជន៍ផ្ទាល់ខ្លួនមួយក្នុងការវិភាគអំពីហានិភ័យ ដែលជនត្រូវចោទអាចដាក់សម្ពាធលើខ្លួន និងវិភាគអំពីហានិភ័យដែលភាគីរដ្ឋប្បវេណីអាច

ស្តីពីគោលការណ៍ ជាមូលដ្ឋាននៃយុត្តិធម៌សំរាប់ជនរងគ្រោះពីឧក្រិដ្ឋកម្ម និងការរំលោភអំណាច (សេចក្តីថ្លែងការណ៍សហប្រជាជាតិ) ត្រូវអនុវត្តក្នុងកម្រិតអប្បបរិមា។ នីតិវិធីព្រហ្មទណ្ឌកម្ពុជាក្តោបនូវគោលការណ៍នានាក្នុងសេចក្តីថ្លែងការណ៍សហប្រជាជាតិ និងរៀបរាប់ល្អិតល្អន់ពីគោលការណ៍ដើម្បីឱ្យភាគីរដ្ឋប្បវេណីនិមួយៗទទួលបានប្រយោជន៍ផ្ទាល់ខ្លួនក្នុងគ្រប់ផ្នែកទាំងអស់នៃរឿងក្តី តាមរយៈសិទ្ធិចូលរួមរបស់ខ្លួននៅគ្រប់កម្រិតទាំងអស់នៃកិច្ចដំណើរការនីតិវិធី រហូតដល់ ការចេញសាលក្រមចុងក្រោយ។

១៣. នៅក្នុងប្រសាសន៍របស់ ឯកឧត្តម សុខ អាន "អនុវត្តតាមនីតិវិធីព្រហ្មទណ្ឌជាតិ អ.វ.ត.កគឺជាតុលាការទីមួយហើយ ដែលមានការចូលរួមជាអន្តរជាតិ ហើយអនុញ្ញាតឱ្យមានឋានៈ ជាភាគីរដ្ឋប្បវេណីពេញលេញទៅឱ្យជនរងគ្រោះ។ ក្នុងស្ថានភាពនេះ ប្រព័ន្ធតុលាការកម្ពុជា និងតុលា ការនេះអាចធ្វើគំរូមួយសំរាប់សហគមន៍អន្តរជាតិបាន"[៥]។

១៤. វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ យល់ស្របជាមួយសារណារបស់សហព្រះរាជអាជ្ញា នៅសវនាការលើបណ្តឹងឧទ្ធរណ៍ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៨ នៅពេលលោក ROBERT PETIT សហព្រះរាជអាជ្ញាអន្តរជាតិបាននិយាយថា គួរសន្មតថា វិធាន២៣នៃអ.វ.ត.កបានស្ថិតនៅក្នុងគំនិតរបស់អង្គបុរេជំនុំជម្រះនៅពេលខ្លួនបានធ្វើសេចក្តីសម្រេចពីការកំណត់ថ្ងៃបើកសវនាការ អនុញ្ញាតឱ្យភាគីរដ្ឋប្បវេណីចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនមុនការជំនុំជម្រះ[៦]។ ច្បាស់ហើយថា ចៅក្រមចេញដីកាឱ្យភាគីរដ្ឋប្បវេណីចូលរួមគឺជាការសមស្របក្នុងន័យនៃការចូលរួមជាមួយវិធានផ្ទៃក្នុង។

**II. អ.វ.ត.ក ត្រូវតែអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលផ្តល់អំណាចឱ្យអ្នកធ្វើសេចក្តីសម្រេចមុនការជំនុំជម្រះ ដើម្បីចេញដីកាឱ្យភាគីមួយចំនួនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការលើបណ្តឹងឧទ្ធរណ៍អំពីការឃុំខ្លួនមុនការជំនុំជម្រះ**

---

មានភស្តុតាងបង្ហាញនៅក្នុងសវនាការលើកដំបូង ឬអង្គហេតុ ឬអង្គច្បាប់បន្ថែមដើម្បីពិភាក្សានៅសវនការឧទ្ធរណ៍អំពីមូលហេតុនេះ។

[៥] កំណត់ចំណាំ២*ខាងលើ* ។

[៦] លោកRobert Petit ព្រះរាជអាជ្ញាអន្តរជាតិ "សវនាការនៃអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនបណ្តោះអាសន្ន" ថ្ងៃទី៧-៨ ខែកុម្ភៈ ឆ្នាំ២០០៨។

00170465

E11/40

១៥. ប្រសិនបើអង្គបុរេជំនុំជម្រះរកឃើញថា បញ្ហានៃការចូលរួមពីភាគីរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ ស្តីពីការឃុំខ្លួនមុនការជំនុំជម្រះពុំត្រូវគេរៀបរាប់ក្នុងវិធានផ្ទៃក្នុងនៃអ.វ.ត.កទេ នោះអង្គជំនុំជម្រះត្រូវតែសម្រេច យោងតាមមាត្រា១២(១)នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ដែលចែងថា "នីតិវិធីត្រូវអនុលោមតាមច្បាប់កម្ពុជា"[៧]។

១៦. ដីកា (Express Order) ចេញពីអង្គបុរេជំនុំជម្រះបង្គាប់ឱ្យភាគីរដ្ឋប្បវេណីចូលរួមក្នុងអំឡុងពេលសវនាការឧទ្ធរណ៍ស្តីពីការឃុំខ្លួន អនុវត្តតាមនីតិវិធីច្បាប់ព្រហ្មទណ្ឌកម្ពុជាយ៉ាងពិតប្រាដក ។ មាត្រា២៦០(២)នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាចែងថា ស្ថាប័នដែលទទួលខុសត្រូវចំពោះសវនាការលើបណ្តឹងឧទ្ធរណ៍ អាចស្នើភាគីផ្សេងៗ ព្រមទាំងជនត្រូវចោទ ឱ្យបង្ហាញខ្លួនក្នុងសវនាការដោយផ្ទាល់ និងផ្តល់ភស្តុតាងជូនចៅក្រម[៨]។

១៧. យោងតាមវិធាន៧៧.៣[៩] នៃអ.វ.ត.ក នៅពេលប្រធាននៃអង្គបុរេជំនុំជម្រះបានធ្វើសេចក្តីសម្រេចពីការកំណត់ថ្ងៃបើកសវនាការ សំរាប់បណ្តឹងឧទ្ធរណ៍របស់ នួន ជា ចៅក្រមបានធ្វើសេចក្តីសម្រេចមួយ ដើម្បីអនុញ្ញាតឱ្យភាគីរដ្ឋប្បវេណីចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនមុនការជំនុំជម្រះ។ លោកស្រីចៅក្រមKATINKA LAHUIS បានសួរក្រុមការពារក្តីរបស់ នួន ជា ក្នុងអំឡុងពេលថ្ងៃទីមួយនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ដោយចោទសួរថា"អង្គបុរេជំនុំជម្រះបានសម្រេចបញ្ចូលភាគីរដ្ឋប្បវេណីទៅក្នុងសវនាការថ្ងៃនេះ តាមរយៈ ការចេញសេចក្តីសម្រេចពីការកំណត់ថ្ងៃបើកសវនាការ។ តើលោកមិនយល់ព្រមជាមួយនឹងដីការបស់យើងទេឬ?"[១០]។

---

[៧] មាត្រា១២(១)បន្តថា "នៅពេលដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ *ចូរមើល* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តិឡើងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") មាត្រា១២(១)។

[៨] ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាប្រកាសឱ្យប្រើដោយព្រះមហាក្សត្រថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៩] *ចូរមើល* វិធានផ្ទៃក្នុងនៃអ.វ.ត.ក ថ្ងៃទី១ ខែកុម្ភះ ឆ្នាំ២០០៨ (វិធានផ្ទៃក្នុងអ.វ.ត.ក) វិធាន៧៧.២។

[១០] លោកស្រីចៅក្រម KATINKA LAHUIS ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ សវនាការរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី៧-៨ ខែកុម្ភះ ឆ្នាំ២០០៨។

១៨. វាជាទស្សនៈរបស់វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យដែលថា ដីកានេះត្រូវបានធ្វើឡើងស្របតាម មាត្រា២៦០(២) នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ហើយថា អ.វ.ត.កត្រូវតែអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលផ្តល់អំណាចឱ្យអ្នកធ្វើសេចក្តីសម្រេចមុនការជំនុំជម្រះ ដើម្បីចេញដីកាបង្គាប់ឱ្យភាគីមួយចំនួន ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការលើបណ្តឹងឧទ្ធរណ៍អំពីការឃុំខ្លួនមុនការជំនុំជម្រះ។

១៩. មាត្រា១២(១)នៃច្បាប់ស្តីពីបង្កើតអ.វ.ត.ក គឺជាយន្តការសំខាន់មួយសំរាប់ការបង្កើត អ.វ.ត.ក។ ស្តីពីបញ្ហាថាតើអ្នកធ្វើសេចក្តីសម្រេចមុនការជំនុំជម្រះ អាចចេញដីកាបង្គាប់ឱ្យភាគីមួយចំនួនចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន នីតិវិធីព្រហ្មទណ្ឌគឺមានលក្ខណៈច្បាស់លាស់ ហើយ។ ជាការពិតក្នុងករណីនេះ គឺភាគីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានចៅក្រមបង្គាប់ឲ្យបង្ហាញខ្លួន ក្នុងកិច្ចដំណើរការនីតិវិធីរួចមកហើយ ម្យ៉ាងទៀតខ្លួនមានឋានៈ ពេលលេញជាគូភាគីមួយក្នុង កិច្ចដំណើរការនីតិវិធីនេះ។ ការរឹតត្បិតទៅលើអ្វីដែលចៅក្រមបានបង្គាប់ដោយត្រឹមត្រូវរួចទៅហើយ អាចនឹងបង្ករឲ្យផលប៉ះពាល់ខ្លាំងដល់ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី បើទោះបីជាមាន ទស្សនៈមួយចំនួនយល់ថាវត្តមានរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនេះគឺជាការវាយប្រហារមួយជា ប្រចាំចាប់តាំងពីដើមទីនៃកិច្ចដំណើរការនីតិវិធីយ៉ាងណាក៏ដោយ។

## III. ការចូលរួមពីភាគីរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនមុនការជំនុំជម្រះ មិនធ្វើឱ្យប៉ះពាល់ដល់ជនជាប់ចោទទេ

២០. វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ មិនឯកភាពជាមួយនឹងអំណះអំណាងរបស់ចៅក្រមការពារក្តីរបស់នួន ជា ដែលថា ការចូលរួមពីភាគីរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួននួន ជា បានរំលោភដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ហើយថាខ្លួនចង់បានដីកាបង្គាប់ជាទូទៅមួយ ដែលគ្មានការចូលរួមពីភាគីរដ្ឋប្បវេណី ដើម្បីការពារសិទ្ធិរបស់ នួន ជា។ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យយល់ស្របថា សារណារបស់ភាគីរដ្ឋប្បវេណីពុំត្រូវបង្ហាញក្នុងមធ្យោបាយមួយដែលធ្វើឱ្យប៉ះពាល់ដល់ជនជាប់ចោទឡើយ។ ចៅក្រមអាចទាត់ចោលភស្តុតាង នៅពេលណាភស្តុតាងនោះបង្ហាញថា វាបណ្តាលឱ្យប៉ះពាល់ និងហួសពីតម្លៃនៃភស្តុតាង។

២១. បើទោះបីជា សារណារបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាឯកសារដែលមានមូលដ្ឋានផ្អែកលើភស្តុតាងយ៉ាងណាក៏ដោយ ក៏ការទាត់ចោលការចូលរួមរបស់ពួកគាត់ទាំងស្រុង មុន

មានការធ្វើសវនាការលើសារណារទាំងនោះជាមុន គឺដូចជាការច្របាច់កការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីអញ្ចឹង។ ក្នុងសារណាទាំងនោះ អាចនឹងមានព័ត៌មានសំខាន់ និងគួរឱ្យទុកចិត្តបានសម្រាប់ជួយឱ្យចៅក្រមធ្វើសេចក្តីសម្រេច ក៏ថាបាន។

២២. នៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន ភាគីរដ្ឋប្បវេណីត្រូវបង្ហាញការគាំទ្រដល់ការចោទប្រកាន់ មិនត្រឹមតែជាដើមបណ្តឹងដាច់ដោយឡែក ឬព្រះរាជអាជ្ញាប៉ុណ្ណោះទេ។ ទូទាំងកិច្ចដំណើរការនីតិវិធី ពួកគេមិនអាចមានសិទ្ធិទាំងស្រុងក្នុងការសួរសំនួរ ឬមិនអាចមានសិទ្ធិចំពោះសារណានានាបានទេ ប៉ុន្តែពួកគេមានសិទ្ធិចូលរួមពេញលេញជាភាគីមួយដែលត្រូវបានគេរក្សាទុកឱ្យ។ ការបញ្ចូលភាគីរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីនៅអ.វ.ត.ក ធ្វើឱ្យប្រែប្រួលដល់មាត្រដ្ឋាននៃយុត្តិធម៌ពីភាគីពីរទៅភាគីច្រើនថែមទៀត។ ប៉ុន្តែនេះមិនមានន័យថា មាត្រដ្ឋានទាំងនោះថិតក្នុងទិសដៅណាមួយនោះ ទេ។ ការបញ្ចូលភាគីរដ្ឋប្បវេណីឱ្យទៅជាអ្នកចូលរួម គឺជាមូលដ្ឋានគ្រឹះមួយសំរាប់ប្រព័ន្ធតុលាការ កម្ពុជា ហើយជាពិសេសអ.វ.ត.ក ដែលជនរងគ្រោះមានចំនួនច្រើនលើសលប់។

### *សេចក្តីសន្និដ្ឋាន*

២៣. ដើម្បីកម្រិតសិទ្ធិចូលរួមពេញលេញពីភាគីរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីតុលាការនៃបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនមុនការជំនុំជម្រះគឺផ្ទុយទៅនឹងនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដោយហេតុថាចៅក្រមបានចេញដីកាឱ្យភាគីផ្សេងៗចូលរួមដែរ។ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យគឺអង្គការមួយបានប្តេជ្ញាអប់រំពលរដ្ឋអំពីសិទ្ធិរបស់ពួកគេក្រោមច្បាប់ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យគាំទ្រចំពោះការចូលរួមពេញលេញពីភាគីរដ្ឋប្បវេណី ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីអ.វ.ត.ក ដោយហេតុថាការចូលរួមនេះត្រូវប្រតិបត្តិតាមវិធាននានានៃច្បាប់ព្រហ្មទណ្ឌកម្ពុជា។ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យក៏សូមគាំទ្រផងដែរដល់ដីកាទាំងឡាយរបស់ចៅក្រម ដែលធ្វើឡើងស្របតាមច្បាប់ព្រហ្មទណ្ឌកម្ពុជាជាធរមាន ដូចជា ដីកាបង្គាប់ឱ្យភាគីនានាចូលរួមក្នុងសវនាការស្តីពីការឃុំខ្លួនមុនការជំនុំជម្រះ។ ក្នុងហេតុផលនេះ យើងសូមជំរុញឱ្យតុលាការធានាថា តុលាការដំណើរការទៅក្នុងលក្ខណៈមួយគាំទ្រគ្រប់ពេលដល់សិទ្ធិជាមូលដ្ឋាននៃអ្នកបង្ហាញខ្លួនចំពោះមុខតុលាការ ដូចជា ជនជាប់ចោទ សាក្សី ឬជនរងគ្រោះ។